ស្តង់ដារពិការភាព
សំរាប់ការអប់រំ



# រឿងរបស់យើង: បទពិសោធន៍ផ្ទាល់ខ្លួននៃក្មេងដែលមានពិការភាពក្នុង ប្រព័ន្ធអប់រំ

នេះជារឿងផ្ទាល់ខ្លួនដែលចែករំលែកនូវបទពិសោធន៍របស់សិស្សដែលមានពិការភាពក្នុងអំឡុងពេលអប់រំរបស់គេ។

ធនជាននេះត្រូវបានផ្ទៃរួមគ្នាដោយសិស្សនិងក្មេងដែលមានពិការភាព និងមាតាបិតា និងអ្នកថែរក្សារបស់គេ។

## អំពីធនធាននេះ

ធនធាននេះត្រូវបានទទួលមូលនិធិពីរដ្ឋាភិបាលអូស្ត្រាលី។
វាត្រូវបានធ្វើដោយសិស្សដែលមានពិការភាពនិងមាតាបិតានិងអ្នកថែរក្សារបស់គេ
រួមនឹងជំនួយពី**កុមារនិងក្មេងដែលមានពិការភាពអូស្ត្រាលី** (Children and Young People with Disability Australia - CYDA) ហើយនិង**សម្ព័ន្ធពិការភាពជាតិសាសន៍ជាតិ** (National Ethnic Disability Alliance - NEDA)។

រដ្ឋាភិបាលអូស្ត្រាលីទទួលស្គាល់ម្ចាស់ទឹកដីដើមនិងអ្នកថែរក្សាប្រទេសទូទាំងប្រទេសអូស្ត្រាលី។ យើងទទួលស្គាល់ដល់ទំនាក់ទំនងដ៏និរន្តន៍ជាមួយដី ទឹក និងសហគមន៍របស់គេ។
យើងសូមគោរពដល់ពួកគេនិងដល់ពួកចាស់ទុំពីអតីតកាលនិងបច្ចុប្បន្នកាល។
យើងសូមគោរពដល់ការអនុវត្តផ្នែកវប្បធម៌ ព្រលឹងវិញ្ញាណ និងការអប់រំនៃជនអាបូរិជិនល និងពួកកោះ Torres Straight។

## កំណត់សំគាល់ពីភាសា

ធនធាននេះប្រើភាសាបុគ្គលមុន (ឧ. សិស្សដែលមានពិការភាព)។ ប៉ុន្តែវិធីនេះមិនសមនឹងមនុស្សគ្រប់រូប ហើយមនុស្សជាច្រើនចូលចិត្តភាសាអត្តសញ្ញាណមុន (ឧ. សិស្សពិការ)។

វាសំរេចទៅលើបុគ្គលម្នាក់ៗ ដែលគេជ្រើសរើសសំគាល់ខ្លួនដោយរបៀបណានោះ។
យើងសូមលើកទឹកចិត្តអ្នកអោយសួរគេថាគេចូលចិត្តអ្វី។
យើងក៏ទទួលស្គាល់ប្រវត្តិសាស្ត្រដ៏ជ្រាលជ្រៅដែលនៅពីក្រោយពាក្យទាំងនេះដែរ។

ពាក្យ 'ការកែសំរួលសមហេតុសមផល' 'ការកែសំរួល' ឬ'ការសំរបតាម' ត្រូវបានគេប្រើសំដៅទៅលើន័យតែមួយ។ យើងប្រើពាក្យទាំងនេះឆ្លះគ្នាក្នុងធនធាននេះ។ 'ការកែសំរួលសមហេតុសមផល' ត្រូវបានប្រើក្នុង ***ច្បាប់រើសអើងពិការភាព 1992*** *(Disability Discrimination Act 1992)*។

## ធនធានបន្ថែម

នេះគឺមួយផ្នែកនៃធនធានមួយក្រុម។ អ្នកអាចរកឃើញនៅក្នុងវ៉ិបសៃត៍នៃក្រសួងអប់រំ ឬដោយស្កេនកូដ QR.

ស្កេនកូដ QR

ធនធាននេះក៏មាននៅក្នុង Easy Read, Auslan និងភាសាផ្សេងៗមួយចំនួនទៀត។ អ្នកអាចចូលមើលសំណេរទាំងនោះនៅវ៉ិបសៃត៍ Australian Government Department of Education ឬ ដោយស្កេនកូដ QR.

***កំណត់សំគាល់មាតិកា:*** *រឿងទាំងនេះមានឧទាហរណ៍ពីការប្រកាន់ ការញែកចេញ និងការរើសអើង។ សំរាប់ជំនួយគាំទ្រ សូមទូរស័ព្ទមក Lifeline តាមលេខ 13 11 14 ឬផ្ញើសារតាមលេខ 0477 13 11 14.*

## ធនធាននេះគឺសំរាប់អ្នកណា

ធនធាននេះចែករំលែករឿងពិតរបស់ក្មេងដែលមានពិការភាព។ ក្នុងនោះគេនិយាយអំពីៈ

1. បទពិសោធន៍របស់គេក្នុងការអប់រំ
2. អ្វីដែលគេបានរៀនពីបទពិសោធន៍ទាំងនេះ
3. អ្វីដែលគេចង់អោយអ្នកដឹង។

បទពិសោធន៍របស់គេខុសគ្នាទាំងអស់ ហើយសំខាន់ទាំងអស់។ រួមទាំងអស់ គេប្រាប់ពីរឿងមួយអំពីរបៀបអនុលោមតាម*ស្តង់ដារពិការភាពសំរាប់ការអប់រំ2005 (Disability Standards for Education 2005)* (DSE) នៃការអប់រំ និងពីរបៀបដែលគេអាចគាំទ្រសិស្សអោយបានប្រសើរឡើង។

## អ្នកមុននឹងអ្នកចាប់ផ្តើម

អ្នកអាចយល់ដឹងថែមទៀតអំពីសិទ្ធិរបស់អ្នកក្រោមស្តង់ដារDSE ។

បន្ទាប់មកសូមឆែកមើលៈ

- រឿងរបស់ឡិល្លី
- រឿងរបស់ដានីញែល

**ការបដិសេធៈ** រឿងទាំងនេះជាពាក្យមតិ និងបទពិសោធន៍របស់ក្មេងដែលចូលរួមក្នុងប្រូចិកនេះ។

# រឿងរបស់ឡិល្លី

**កំណត់សំគាល់មាតិកា:** មាននិយាយពីការប្រកាន់និងការញែកចេញ

នៅសាលាបឋមសិក្សាខ្ញុំមានអារម្មណ៍មិនស្រួលទៅហើយក្នុងចំណោមហ្វូងមនុស្ស។ ធំឡើងក្នុងគ្រួសារជាអ្នកចំណូល ស្រុកដែលពុំមានការយល់ដឹងផ្នែកវប្បធម៌ ឬក្របខ័ណ្ឌសំរាប់ពិការភាព ឬសុខភាពផ្លូវចិត្ត ខ្ញុំក៏មានការពិបាកយល់មូលហេតុដែលចូលនឹងគេមិនចុះ ឬថាត្រូវទៅចូលនឹងអ្វី។

បន្ទាប់ពីខ្ញុំបានចេញទៅរៀននៅបរទេស ខ្ញុំក៏មានឃើញវប្បធម៌ថ្មី និងមនុស្សដែលចង់និយាយជាមួយខ្ញុំអំពីសភាពពិតរបស់ខ្ញុំ និងពីហេតុដែលខ្ញុំមិនបានឈោងដល់សក្តានុពលរបស់ខ្ញុំ។ ពួកគេពិតជាចង់គាំទ្រនិងណែនាំខ្ញុំមែនទែន។ នេះជាលើកទីមួយដែលខ្ញុំដឹងថាខ្ញុំជាផ្នែកមួយនៃសហគមន៍ដែលមានបទពិសោធន៍រស់នៅស្រដៀងគ្នា ហើយថា ទាំងអស់គ្នា យើងមានសមត្ថភាពនិងអំណាចលើរបៀបកសាងមនុស្សជំនាន់អនាគត។

> ទោះជាខ្ញុំមិនបាននៅអូស្ត្រាលីក្តី ទូទាំងពិភពលោកខ្ញុំក៏បានដឹងជាលើកដំបូងថា ការទទួលការអប់រំជាសិទ្ធិដែលគេទទួលស្គាល់ថាសំរាប់មនុស្សទាំងអស់ ហើយថាសាលាទាំងឡាយត្រូវផ្តល់ដល់ជនមានពិការភាពដូចខ្ញុំ នូវការកែសំរួល និងការគាំទ្រដើម្បីអោយទទួលបាន។

តាំងពីពេលនោះមក ខ្ញុំមានបទពិសោធន៍ចំរុះ ដែលបានធ្វើការជាមួយអ្នកវិជ្ជាការ និងស្ថាប័ននានាដើម្បីគាំទ្រអោយខ្លួនខ្ញុំ។ អ្នកខ្លះប្រហែលមានការយល់ដឹងពីពិការភាពច្បាស់លាស់ដោយសារប្រវត្តិ និងបទពិសោធន៍របស់គេ ហើយក៏មិនក្រាញនឹងធ្វើការសន្ទនាអំពីតំរូវការរបស់ខ្ញុំ។ ប៉ុន្តែបើមើលពីទស្សនៈនៃស្ថាប័នវិញ ខ្ញុំត្រូវបានធុញថប់ម្តងហើយម្តងទៀតដោយដំណើរការយឺត ការទាក់ទងមិនល្អ និងតំរូវការដែលគ្មានការយោគយល់ - ជាពិសេសនៅពេលផ្តល់ក្រដាសស្នាមពេទ្យនិងឯកសារនានាដើម្បីបង្ហាញអ្វីដែលខ្ញុំ គិតថាមិនគួរធ្វើសោះ។

+

បន្ទាប់ពីបានទទួលការកែសំរួលហើយ ឃើញថាមានឥទ្ធិពលខ្លាំងគួរ។ ខ្ញុំអបអរណាស់ដែលបន្ទាប់ពីបានលោតឆ្លងកាត់ឧបសគ្គមួយចំនួនមក ស្ថាប័នទាំងឡាយច្រើនតែសំដែងការយោគយល់យ៉ាងខ្លាំងស្ដីពីការកែសំរួលនិងការកែប្រែមួយចំនួនធំ ដើម្បីជួយគាំទ្រខ្ញុំនិងមិត្តស្រករខ្ញុំ។ ទោះជាយ៉ាងណា ពួកគេត្រូវការអភិវឌ្ឍនិងបង្កើតឧបករណ៍និងព័ត៌មានដើម្បីគាំទ្រសិស្សពេលគេដាក់ពាក្យសុំ ហើយនិងដើម្បីធ្វើអោយក្មេងជំនាន់ក្រោយបានឃើញដឹងឮច្បាស់ជាងមុន ហើយថាការគាំទ្រទាំងនេះគឺមានសំរាប់ពួកគេ។

> ចំពោះក្មេងដទៃទៀតដែលស្ថិតក្នុងស្ថានភាពស្រដៀងខ្ញុំ ខ្ញុំចង់បញ្ជាក់ថា អ្នកមិនចំឡែកទេ អ្នកមិនខុសពីធម្មតាទេ ហើយក៏មិននៅឯកោតែឯងដែរ។

ការសរសេររឿងនេះត្រូវបានជាបទពិសោធន៍ដ៏ជាក់លាក់ និងប្រៀបដូចជារង្វាន់មួយសំរាប់ខ្ញុំ។ ការមានឱកាសចែករំលែកជាមួយមិត្តស្រករគ្នាដោយយមិនលាក់បាំង ដោយគ្មានគេវិនិច្ឆ័យ គឺជាអ្វីដែលខ្ញុំត្រូវថ្លែងអំណរគុណ។ ចូរចាំថា បើអ្នកត្រូវការជំនួយ ឬមានរម្មណ៍ថាអ្នកវង្វេង សូមប្រឹងអស់ពីសមត្ថភាពដើម្បីឈោងមក ហើយអ្នកនឹងដឹងថា យើងនៅទីនេះសំរាប់អ្នក ហើយនៅទីនេះសំរាប់ជួយ។ ខ្ញុំដឹងថាការដែលអ្នកធ្វើអោយខ្លួនងាយនឹងរងគ្រោះគឺវាពិបាក ប៉ុន្តែចូរដឹងថាគឺនៅគ្រានោះហើយដែលនឹងនាំអ្នកមករកការរៀនដឹង លូតលាស់ និងកំឡាំងពលំថែមទៀត។

*

# រឿងរបស់ដានីញែល

**កំណត់សំគាល់មាតិកា:** មាននិយាយពីការប្រកាន់ ការញែកចេញ កាទប់ខ្លួនមិនប្រើជាតិគីមី និងការធ្វើបាបពីគ្រូ។

## សាលាបឋមសិក្សា

បទពិសោធន៍របស់ខ្ញុំជាមួយការអប់រំបានឆ្លងកាត់ពេញវិសាលគតែម្តង ពីអវិជ្ជមានទៅវិជ្ជមាន និងគ្រប់យ៉ាងក្នុងចន្លោះ។ ខ្ញុំជាមនុស្សកើតអូទីស្ស៊ីម ហើយមានវិបល្លាសសកម្មភាពលើសលប់ខ្វះការតាំងស្មារតី (attention deficit hyperactivity disorder - ADHD) និងវិបល្លាសថប់បារម្ភ។

ខ្ញុំចាំកាលមាន'អាកប្បកិរិយា'យ៉ាង'ពិបាក'បំផុតនៅសាលាបឋមសិក្សា - នេះបើតាមអ្វីដែលគ្រូៗខ្ញុំប្រាប់ម្តាយខ្ញុំ។ បទពិសោធន៍សាលាបឋមសិក្សារបស់ខ្ញុំត្រូវបានគ្រូតែងតែ រៀបរាប់ក្នុងរបាយការណ៍ថា 'ដានីញែលជាសិស្សឆ្លាតម្នាក់ មានសក្តានុពលច្រើន ប៉ុន្តែមានភាពលំបាកក្នុងការគ្រប់គ្រង ខ្លួនឯងក្នុងថ្នាក់រៀន និងក្នុងការតាំងស្មារតីអោយមុតដើម្បីបំពេញភារកិច្ច។'

ខ្ញុំដឹងច្បាស់ថាប្រយោគនេះនៅតែមានបោះទៅមកកាត់ទីអប់រំជាច្រើនសំរាប់សិស្សជាច្រើន។

ខ្ញុំមានការពិបាកនឹងអង្គុយនៅស្ងៀម។ ខ្ញុំនិយាយកាត់គេ ប្រើឃ្លាមិនសមរម្យ (ឬពេលតែអ្វីៗអោយត្រូវនឹងការតាំងខ្លួនជា តួកប្រចាំថ្នាក់)។ ខ្ញុំខ្វះបញ្ញាផ្នែកមនោសញ្ចេតនា និងការតស៊ូពេលប្រទះឧបសគ្គ។ ខ្ញុំត្រូវបានពេទ្យសំគាល់ថាមាន ADHD ហើយត្រូវលេបថ្នាំពេញអំឡុងសាលាបឋមសិក្សា។

> ខ្ញុំតែងតែមានអារម្មណ៍ថាគេបំបរបង់ចោលដោយព្រោះតែត្រូវទៅការិយាល័យរាល់ពេលបាយថ្ងៃត្រង់ដើម្បីយកថ្នាំ ADHD ថែមទៀត។

ខ្ញុំមានការខ្វែងគំនិតជាច្រើនលើកជាមួយគ្រូៗ មិនព្រមធ្វើភារកិច្ច ហើយឈ្លោះជាមួយគ្រូដែលមិនព្រមអោយខ្ញុំធ្វើអ្វីតាមរបៀបរបស់ខ្ញុំ។ ខ្ញុំក៏មានការតទល់បែបនេះជាមួយមិត្តស្រកខ្ញុំដែរ។ ពេលនឹកពិចារណាឡើងវិញ ខ្ញុំក៏បានដឹងថាការនេះគឺវាទាក់ទងទៅនឹងអូទីស្ស៊ីមដែលកាលនោះមិនទាន់បានវិនិច្ឆ័យឃើញនៅឡើយ។ ខ្ញុំនៅចាំច្បាស់ពីសិស្សម្នាក់ទៀតដែលមកយកជ័រស្អិតដែលខ្ញុំកំពុងលែង។ ខ្ញុំបានសុំគាត់វិញដោយសុភាព តែគាត់មិនព្រម។ ស្រាប់តែ ខ្ញុំចាំថាសាទៅមុខទៅការិយាល័យចាងហ្វាងជាមួយសិស្សនោះដែលមានជ័រស្អិតជាប់សក់គាត់! មិនជាគ្រាល្អបំផុតរបស់ខ្ញុំទេ។ ខ្ញុំបានឆ្លងកាត់សាលា បឋមសិក្សាទាំងមានបញ្ជីឧប្បត្តិហេតុមួយ ហើយមិនសូវមានទំនុកចិត្តលើខ្លួនជាសិស្សប៉ុន្មានទេ លើកលែងការប្រឡង មេគុណដែលខ្ញុំឈ្នះលើគេរហូត។

ក្នុងនាមជាមនុស្សពេញវ័យម្នាក់ ខ្ញុំបានរៀនដឹងអំពី *ស្តង់ដារពិការភាពសំរាប់ការអប់រំ 2005 (Disability Standards for Education 2005)*។ ពេលខ្ញុំមើលទៅក្រោយវិញ ខ្ញុំគិតថាសាលាខ្ញុំគួរតែធ្វើថែមលើសនោះ ដើម្បីជួយគាំទ្រខ្ញុំ។ គួរតែប្រសើរជាងនោះបើពួកគាត់សួរខ្លួនឯងថា 'ហេតុអ្វីបានការនេះកើតឡើង?' ឬសួរខ្ញុំមក! នោះយើង គួរតែបានធ្វើការជាមួយគ្នាដើម្បីធ្វើការកែសំរួលដែលគាំទ្រខ្ញុំអោយរៀន ហើយអោយបានរាប់បញ្ចូលទៀត។

# អនុវិទ្យាល័យ

ខ្ញុំចាំសកម្មភាពទីមួយដែលយើងបានធ្វើ។
ថ្នាក់ត្រូវធ្វើជាក្រុមកាលនៅក្នុងរោងកីឡាដ៏ធំមួយដែលមានសំឡេងឡូងដ៏ខ្លាំងបំពងកាត់លំហអាកាស។
ខ្ញុំចាំព្រោះមិនបានឮឬគិតថាគេអោយខ្ញុំទៅថ្នាក់ណាទេ។
ដូច្នេះក៏ធ្វើអោយខ្ញុំដើរជុំវិញសាលាអស់៣០នាទីរកថ្នាក់រៀនរបស់ខ្ញុំ។ ក្រៅពីនេះ
អនុវិទ្យាល័យជាបទពិសោធន៍វិជ្ជមានដ៏ខ្លាំង សំរាប់ខ្ញុំ។ ខ្ញុំត្រូវបានពេទ្យសំគាល់ថាមានអូទីស្សឹម
ហើយត្រូវបានផ្តល់ឱកាសអោយកែប្រែថ្នាក់និងគ្រោងនានា របស់ខ្ញុំ ដើម្បីគាំទ្រគោលដៅផ្ទាល់ខ្លួនរបស់ខ្ញុំ។

ដោយព្រោះខ្ញុំបានរៀនគណិតសាស្ត្រថ្នាក់ទី១២កាលនៅថ្នាក់ទី១១ ខ្ញុំក៏ត្រូវបានផ្តល់ឱកាសអោយដក
មេរៀនមួយពីចំណោមមេរៀនថ្នាក់ទី១២។ បូករួមនឹងការសំរាកពីសិក្សាបន្ថែមផង មានន័យថា
កាលវិភាគថ្នាក់ទី១២របស់ខ្ញុំត្រូវចាប់ពីម៉ោង 8:30 ព្រឹក - 1:30 ថ្ងៃត្រង់ ថ្ងៃច័ន្ទទៅថ្ងៃសុក្រ។

ពេលនោះ ខ្ញុំធ្វើការមិនពេញម៉ោង ហើយត្រូវបានផ្តល់ Certificate IV ក្នុងការលក់ដូរ
ដែលជាផ្នែកមួយនៃការអភិវឌ្ឍជំនាញការចាត់ចែងក្នុងការងាររបស់ខ្ញុំ។ ការនេះក៏បន្ថែមដល់
លំដាប់ថ្នាក់ Australian Tertiary Admission Rank (ATAR) របស់ខ្ញុំដែរ។
នេះក៏បណ្តាលអោយខ្ញុំបានរៀនពេលថ្ងៃ
ហើយចេញទៅធ្វើការបានប្រាក់កាសរស់នៅយ៉ាងធូរជាមួយសំរាប់ក្មេងអាយុ១៧ឆ្នាំ។

ខ្ញុំមានអំណរដ៏លើសលប់ចំពោះសមត្ថភាពរបស់សាលាខ្ញុំដែលបានស្តាប់ដល់គោលដៅនិងតំរូវការរបស់ខ្ញុំ
ហើយបានរាប់បញ្ចូលផងដែរនៅពេលរៀបចំគ្រោងអប់រំរបស់ខ្ញុំ។
ខ្ញុំក៏បានទទួលការសំរបសាមញ្ញផងដែរពេលប្រឡង ដូចជា សំរាកបានយូរ ម្ហូបក្នុងការប្រឡង
ហើយនិងអាចដើរជុំវិញបន្ទប់ប្រឡង។ ប៉ុន្តែដើម្បីធ្វើដូច្នេះបាន ខ្ញុំត្រូវ បានគេដាក់ក្នុងលំហដោយឡែកមួយ
ដែលខ្ញុំមានអារម្មណ៍ថាញែកដោយឡែកពន់ពេកណាស់
ក្នុងពេលមិត្តស្រករខ្ញុំមានឱកាសនិយាយលែងសើចនិងចៅរៅគ្នាក្រៅបន្ទប់ប្រឡងមុនពេលប្រឡង។

គួរអោយចាប់អារម្មណ៍ដែរ ដែលខ្ញុំមិនដែលបានឃើញសំណេរឯកសារអ្វីដែលប្រាប់ខ្ញុំអំពីសិទ្ធិរបស់ខ្ញុំក្រោម
ស្តង់ដារ DSE។ ខ្ញុំដឹងថាសាលាអាចធ្វើការកែសំរួលសមហេតុផល ប៉ុន្តែគេបង្ហាញមកខ្ញុំបែប 'ខ្ញុំអាចទទួល
ជំរើស**ទាំងនេះ**' មិនមែន 'ខ្ញុំគួរតែបានពិភាក្សាអំពីការកែសំរួលសមហេតុផល**អ្វី**ដែលអ្នកត្រូវការចូលរួមក្នុង
ការអប់រំ'។ ខ្ញុំរីករាយនឹងអ្វីដែលសាលាខ្ញុំបានធ្វើសំរាប់ខ្ញុំ
ប៉ុន្តែពេលមើលទៅក្រោយវិញវាហាក់ដូចជាគ្រប់គ្រងខ្ញុំពេក
បើទោះជាគេធ្វើត្រូវទាំងស្រុងភាគច្រើនក៏ដោយ។

# ការអប់រំមហាវិទ្យាល័យ

បទពិសោធន៍នៃការអប់រំរបស់ខ្ញុំបន្ទាប់មកគឺបរិញ្ញាតន្ត្រីនៅសកលវិទ្យាល័យ។ សកលវិទ្យាល័យដែលខ្ញុំចូលមានការគាំទ្រផ្នែកពិការភាពអន់គួរ។ ពួកគេពុំបានផ្តល់ធនធាន ឬអោយឱកាសខ្ញុំដាក់ពាក្យសុំការគាំទ្រទេ។ ឥឡូវនេះខ្ញុំដឹងថា នេះជាការដែលពួកគេគួរតែបានធ្វើយោលទៅតាមស្តង់ដារ DSE។ ខ្ញុំត្រូវបានគ្រូម្នាក់រករឿងដោយព្រោះគាត់មិនចូលចិត្តបុគ្គលិកលក្ខណៈរបស់ខ្ញុំ (ឬដោយការដែលខ្ញុំនៅមិនស្ងៀមដែលអាចបណ្តាល មកពី ADHD)។

**សរុបទៅ សកលវិទ្យាល័យបានធ្វើខុស ហើយនេះក៏បណ្តាលអោយខ្ញុំមិនបានចូលថ្នាក់នានា មិនបានចូលថ្នាក់រៀនបន្ថែម ហើយនិយាយរួមទៅក៏មិនបាន ចូលរួមនៅសកលវិទ្យាល័យតែម្តង។**

មានពេលច្រើនលើកណាស់ដែលខ្ញុំចង់ទំលាក់ចេញពីថ្នាក់ទាំងអស់(ហើយត្រូវប្រើបណ្តាញគាំទ្រក្រៅសាលាដើម្បីទាក់ទាញខ្ញុំអោយនៅរៀន)។ សរុបទៅ ខ្ញុំត្រេកអរក្រៃលែងដែលបានកន្លាសមួយសន្លឹកដើម្បីបញ្ចប់បទពិសោធន៍។

បន្ទាប់ពីខ្ញុំសំរេចចិត្តឈប់ដេញតាមក្តីសុបិន្តចង់ធ្វើអ្នកជំនាញខាងតន្ត្រីមក ខ្ញុំក៏សំរេចចិត្តទៅសកលវិទ្យាល័យវិញ ហើយទីបំផុតក៏បានសិក្សាបរិញ្ញានៃវិទ្យាសាស្ត្រចិត្តវិទ្យា។ នៅឆ្នាំទីមួយរបស់ខ្ញុំ ខ្ញុំក្រាញនឹងចុះឈ្មោះទទួលសេវាគាំទ្រពិការភាពបន្ទាប់ពីបទពិសោធន៍របស់ខ្ញុំនៅអតីតសកលវិទ្យាល័យរបស់ខ្ញុំ។ ខ្ញុំមានគ្រាអំនួតដ៏ចំឡែកមួយ ពេលខ្ញុំចង់បង្ហាញថាខ្ញុំអាចធ្វើបទពិសោធន៍សកលវិទ្យាល័យទាំងមូលដោយគ្មានការគាំទ្របន្ថែម - ប៉ុន្តែខ្ញុំក៏ដឹងថាធ្វើដូច្នេះនឹងមិនផ្តល់តំលៃដល់ខ្ញុំទេ។ កាលនោះខ្ញុំបានធ្វើការក្នុងវិស័យពិការភាព ហើយក៏បានដឹងថាការគាំទ្រមានប្រយោជន៍ប៉ុណ្ណាដល់ជីវិតអ្នកមានពិការភាព។ ខ្ញុំបានដឹងថាខ្ញុំមានសិទ្ធិនឹងទទួលការគាំទ្រទាំងនេះក្នុងការ អប់រំក្រោមច្បាប់អូស្ត្រាលី។

ខ្ញុំបានសំរេចចិត្តប្រើសេវាគាំទ្រពិការភាពរបស់សកលវិទ្យាល័យ ហើយក៏បានទទួលការគាំទ្រយ៉ាងច្រើនលើសលប់ ដោយមានការពន្យារពេលកំណត់ ការសំរាកក្នុងពេលប្រឡង និងទីកន្លែងស្ងប់ស្ងាត់កាលនៅបរិវេណសាលា ដើម្បីទ្រទ្រង់ខ្ញុំក្នុងបរិញ្ញារបស់ខ្ញុំ។ខ្ញុំបានទទួលតំលៃដ៏ច្រើនលើសលប់ពីការនេះព្រោះវាធ្វើអោយខ្ញុំមិនប្រឹងសំឡឹងមើលលើអ្វីដែលខុស ហើយក៏ផ្តល់ផ្លូវជួយខ្ញុំបើខ្ញុំយឺតយារ ឬមានការតានតឹងចិត្តដោយព្រោះពេលកំណត់។

ការនេះក៏ទ្រទ្រង់ខ្ញុំអោយធ្វើការពេញម៉ោង កាលកំពុងរៀនសកលវិទ្យាល័យពេញម៉ោង ដែលខ្ញុំអោយតំលៃសំរាប់អាជីព និងគោលដៅថវិការបស់ខ្ញុំ។ នៅចុងបញ្ចប់បរិញ្ញារបស់ខ្ញុំ ខ្ញុំត្រូវបានទទួលអោយចូលរៀន Honours ផ្នែកចិត្តសាស្រ្ត ប៉ុន្តែខ្ញុំបានសំរេចចិត្តបដិសេធ ដើម្បីតាមឱកាសនានានៃអាជីបដ៏រំភើបវិញ។

បើមានអ្វីដែលខ្ញុំសង្ឃឹមថាបណ្តាជនយកបានពីសេចក្តីសង្ខេបនៃបទពិសោធន៍១៨ឆ្នាំជាមួយការអប់រំនេះ គឺថាការគាំទ្រអាចជួយបានមែនពិត។

អ្នកប្រហែលមានអារម្មណ៍ថាអ្នកមិនចង់អោយគេប្រព្រឹត្តមកអ្នកប្លែកពីគេទេ ថាអ្នកមិនត្រូវការការកែសំរួល ឬថាសមត្ថភាពរបស់អ្នកមិនអាស្រ័យទៅលើពិការភាពរបស់អ្នកទេ។ ក៏មិនអីទេ។ ប៉ុន្តែបើអ្នកត្រូវការការគាំទ្រ សូមកុំមានអារម្មណ៍ឯកោឬថាអ្នកមិនគ្រប់គ្រាន់ឡើយ។

គ្រប់ៗគ្នាត្រូវការជំនួយគាំទ្រ មិនថាមានពិការភាពឬមិនមានឡើយ។ តំលៃដែលអ្នកអាចទទួលពីការជំនួយគាំទ្រអាចសអោយឃើញការស្អប់បទពិសោធន៍នៃការអប់រំ ឬការចូលចិត្តវាយ៉ាងខ្លាំង។

## បទពិសោធន៍របស់អ្នកគឺជាទង្វើរបស់អ្នក ដូច្នេះចូរធ្វើវា អោយទៅជារបស់អ្នក។

www.education.gov.au/disability-standards-education-2005